**មាត្រា ៣ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងឡាយ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## ២.សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### សេចក្តីសម្រេចលេខ ០៩ សសរ

### ស្តីពីការផ្ទេរភារកិច្ច

* * *

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅប្រទេសម៉ាឡេស៊ី តាំងពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តមកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រីទី១

ហត្ថលេខានិងត្រា

ហ៊ុន សែន

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

# សេចក្តីសម្រេចលេខ ១០ សសរ

## ស្តីពីការផ្ទេរភារកិច្ច

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសឯកឧត្តម អ៊ឹម ឈុនលឹម ដែលត្រូវអញ្ជើញទៅទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់ឯកឧត្តម អ៊ឹម ឈុនលឹម អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងឯកឧត្តម ឆាយ ថន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***